# COVID-19 ECONOMIC RESPONSE
# PARLIAMENTARIANS' MANIFESTO

ការរីករាលដាលនៃជំងឺ COVID-19 និងការធ្លាក់ចុះសេដ្ឋកិច្ចជាបន្តបន្ទាប់ បង្ហាញឲ្យឃើញពីភាពបរាជ័យ និងភាពផុយស្រួយនៃប្រព័ន្ធសេដ្ឋកិច្ចបច្ចុប្បន្ន ដែលបានផ្តល់អាទិភាពលើផលប្រយោជន៍ពាណិជ្ជកម្មជាង សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងបរិស្ថាន ព្រមទាំងធ្វើឲ្យមានវិសមភាពកាន់តែខ្លាំង និងបរាជ័យក្នុងការការពារជនងាយរងគ្រោះបំផុត។

ហេតុដូចនេះ វាពិតជាមានសារៈសំខាន់ណាស់ដែលយើងត្រូវប្រើប្រាស់វិធានការនានា ដែលមានគោលដៅស្តារសេដ្ឋកិច្ចពីវិបត្តិបង្កដោយការរីករាលដាលនៃជំងឺ COVID-19 នេះឡើងវិញ ដើម្បីងើបផុតពីគ្រោះមហន្តរាយពីអតីតកាលនេះ ហើយផ្លាស់ប្តូរឆ្ពោះទៅរកសេដ្ឋកិច្ចដែលរឹងមាំ ប្រកបដោយចីរភាព និងសមធម៌ ដែលការពារសិទ្ធិមនុស្សរបស់មនុស្សគ្រប់រូប។

ការផ្លាស់ប្តូរឆ្ពោះទៅរកសេដ្ឋកិច្ចកាន់តែបៃតង ដែលជម្រុញឲ្យមានកំណើនការងារសមរម្យ ផ្តល់ការគាំពារសង្គមដល់មនុស្សគ្រប់រូប និងការផ្គត់ផ្គង់ស្បៀងអាហារប្រកបដោយនិរន្តរភាព នឹងមិនត្រឹមតែជួយឲ្យតំបន់នេះអាចកាត់បន្ថយផលប៉ះពាល់ភ្លាមៗនៃវិបត្តិធ្លាក់ចុះនៃសេដ្ឋកិច្ចបានកាន់តែឆាប់រហ័សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឲ្យតំបន់នេះអាចចៀសផុត និងមានភាពកាន់តែរឹងមាំធន់នឹងវិបត្តិ និងគ្រោះថ្នាក់ដ៏រន្ធត់ស្រដៀងគ្នានេះនាពេលអនាគត។

សមាជិកសភាអាចដើរតួយ៉ាងសំខាន់ក្នុងការធានាថា វិធានការនានាដែលមានគោលដៅស្តារសេដ្ឋកិច្ចពីវិបត្តិបង្កដោយការរីករាលដាលនៃជំងឺ COVID-19 នេះឡើងវិញ ជួយជម្រុញឲ្យមានកំណើនសេដ្ឋកិច្ចដែលរឹងមាំ ប្រកបដោយចីរភាព និងសមធម៌ ដែលលើកកម្ពស់ ការពារ និងគោរពសិទ្ធិមនុស្សរបស់មនុស្សគ្រប់រូប។

ហេតុដូចនេះ យើងដែលជាសមាជិកសភាមកពីតំបន់អាស៊ីអាគ្នេយ៍ សូមប្តេជ្ញាប្រើប្រាស់ឋានៈជាសមាជិកសភារបស់ខ្លួន ដើម្បី៖

១. ជម្រុញឲ្យមានកំណើនសេដ្ឋកិច្ច ដែលរក្សាបាននូវកំណើនសីតុណ្ហភាពពិភពលោកឲ្យនៅកម្រិតទាបជាង ១,៥ អង្សាសេ នៅចុងសតវត្សរ៍នេះ ដែលជាកម្រិតធ្វើឲ្យមនុស្សគ្រប់រូប រួមទាំងមនុស្សជំនាន់ក្រោយ អាចប្រើប្រាស់សិទ្ធិមនុស្សរបស់ខ្លួនដោយក្ដីសោមនស្ស ដោយពុំមានភយន្តរាយបង្កដោយការប្រែប្រួលអាកាសធាតុ ការបំពុលបរិស្ថាន ការកាប់បំផ្លាញព្រៃឈើ កាកសំណល់ និងការខូចបរិស្ថាន តាមរយៈ៖

១.១. ការធានាថា វិធានការនានាដែលត្រូវបានអនុម័តដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺ COVID-19 ព្រមទាំងវិបត្តិសេដ្ឋកិច្ចដែលបង្កដោយជំងឺនេះ មិនបានធ្វើឲ្យចុះខ្សោយ ប៉ុន្តែផ្ទុយទៅវិញធ្វើឲ្យកាន់តែរឹងមាំនូវវិធានការការពារបរិស្ថានដែលមានស្រាប់ និងការអនុវត្តវិធានការការពារបរិស្ថាននេះ;

១.២. ការដាក់បញ្ចូលនៅក្នុងចំណាយលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច នូវការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងការគាំទ្រដោយផ្ទាល់បន្ថែមទៀតចំពោះប្រព័ន្ធថាមពលកកើតឡើងវិញ ព្រមទាំងបច្ចេកវិជ្ជា និងហេដ្ឋារចនាសម្ព័ន្ធនៃការបំភាយឧស្ម័នកម្រិតសូន្យ ស្របតាមគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស;

១.៣. ការកំណត់លក្ខខណ្ឌចំពោះជំនួយសេដ្ឋកិច្ចដែលផ្តល់ដល់អង្គភាពនានាក្នុងវិស័យឯកជន រួមទាំងខ្សែសង្វាក់ផ្គត់ផ្គង់របស់អង្គភាពទាំងនោះ ឲ្យមានការថយចុះជាបន្ទាន់នូវកម្រិតនៃការបំពុលបរិស្ថាន ការបំភាយឧស្ម័ន កាកសំណល់ និងផលប៉ះពាល់ដ៏គ្រោះថ្នាក់ផ្សេងទៀតដល់បរិស្ថាន តាមរបៀបដែលស្របជាមួយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ព្រមទាំងស្តង់ដាសិទ្ធិមនុស្ស និងបរិស្ថានអន្តរជាតិដទៃផ្សេងទៀត; និង

១.៤. ធ្វើប្រសើរឡើងនូវរបាយការណ៍នៃការចូលរួមចំណែករបស់ជាតិនៃបណ្តាប្រទេសអាស៊ាន ក្នុងការអនុវត្តតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីធានាថារបាយការណ៍ទាំងនោះស្របជាមួយគោលដៅនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

២. ជម្រុញឲ្យមានកំណើនសេដ្ឋកិច្ច ដែលធ្វើឲ្យមនុស្សគ្រប់រូបទទួលបានការគាំពារសង្គម និងសេវាសាធារណៈចាំបាច់នានាគ្រប់គ្រាន់ ជាពិសេសក្នុងពេលមានវិបត្តិផ្សេងៗ តាមរយៈ៖

២.១. ការធានាថា វិធានការដែលមានគោលដៅឆ្លើយតប និងការពារមនុស្សពីផលប៉ះពាល់នៃការរីករាលដាលនៃជំងឺ COVID-19 បានគិតគូរអំពីផលប៉ះពាល់ដែលមានលក្ខណៈខុសគ្នានៃវិបត្តិទាំងនោះទៅលើជនដែលងាយរងគ្រោះ និងរងផលប៉ះពាល់បំផុត រួមមាន ស្ត្រី ជនចំណាកស្រុក អ្នកស្រឡាញ់ភេទដូចគ្នា ជនពិការ អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួន ជនជាតិដើមភាគតិច កសិករ ជនជាតិភាគតិច និងជនភាគតិចដទៃផ្សេងទៀត និងអ្នកដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ល។;

២.២. ការសម្របសម្រួល ពង្រីករយៈពេល និងពង្រីកទំហំនៃគម្រោងគាំពារសង្គមដល់អ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជនភៀសខ្លួន កម្មករចំណាកស្រុក និងអ្នកដទៃផ្សេងទៀតដែលបច្ចុប្បន្នមិនត្រូវបានរាប់បញ្ចូល; និង

២.៣. ការធានាថា មនុស្សគ្រប់រូបនៅតែមានលទ្ធភាពអាចទទួលបាននូវសេវាសាធារណៈគ្រប់គ្រាន់ នៅក្នុងវិស័យពាក់ព័ន្ធនឹងសុខភាព អប់រំ គមនាគមន៍ ទឹក លំនៅដ្ឋាន និងផ្សេងៗទៀត ក្នុងអំឡុងពេលនៃវិបត្តិ និងដោយគ្មានការរើសអើង។

៣. ជម្រុញឲ្យមានកំណើនសេដ្ឋកិច្ច ដែលផ្ដល់ឱកាសការងារដែលមានសុវត្ថិភាព និរន្តរភាព និងសមរម្យបន្ថែមទៀតដល់មនុស្សគ្រប់រូប ដែលការងារទាំងនោះផ្ដល់ការការពារគ្រប់គ្រាន់ដល់កម្មករទាំងក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធ តាមរយៈ៖

៣.១. ការកំណត់លក្ខខណ្ឌចំពោះជំនួយសេដ្ឋកិច្ចដែលផ្ដល់ដល់អង្គភាពនានាក្នុងវិស័យឯកជន ដោយតម្រូវឲ្យចាត់វិធានការដើម្បីធានា៖

- ក្រុមហ៊ុនសហគ្រាសប្រើប្រាស់វិធីសាស្ត្រសកម្មនិយមក្នុងការគ្រប់គ្រងផលប៉ះពាល់ដ៏គ្រោះថ្នាក់ដល់សិទ្ធិមនុស្ស នៅក្នុងប្រតិបត្តិការទាំងអស់របស់ខ្លួន រួមទាំងប្រតិបត្តិការឆ្លងដែន;

- ការអនុវត្ត និងការការពារដោយត្រឹមត្រូវនូវសិទ្ធិកម្មករអន្តរជាតិ រួមមាន ប្រាក់ខែ និងល័ក្ខខ័ណ្ឌការងារសមរម្យ សិទ្ធិធ្វើការនៅកន្លែងដែលមានសុវត្ថិភាព សេរីភាពរបស់កម្មករក្នុងការជួបប្រជុំ និងបង្កើតសមាគម និងសិទ្ធិក្នុងការចរចាជាសមូហភាព;

- សមភាពយេនឌ័រ ក្នុងការទទួលបានឱកាសការងារ និងឱកាសសម្រាប់ការជ្រើសរើស និងគ្មានការរើសអើងនៅក្នុងប្រាក់ឈ្នួល និងការដំឡើងដំណែង; និង
- កម្មករទទួលបានការងារបន្ត ការបណ្តុះបណ្តាល និងឱកាសការងារដែលប្រសើរជាងមុន។

៣.២. ការអនុម័តវិធានការដែលធានាថា កម្មករក្រៅប្រព័ន្ធ ជនចំណាកស្រុក ស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា កម្មករជាជនពិការ និងក្រុមកម្មករដទៃផ្សេងទៀត មិនត្រូវបានថៅកែរបស់ខ្លួន ឬអ្នកដទៃផ្សេងទៀត ធ្វើឲ្យរងគ្រោះដោយសារផលប៉ះពាល់មិនសមាមាត្រនៃវិបិត្ត;

៣.៣. ផ្តល់អាទិភាពលើវិធានការណាដែលជួយ និងជម្រុញឲ្យមានកំណើនការងារ និងប្រាក់ចំណូល តាមរយៈ៖

- ការវិនិយោគលើការបង្កើតឱកាសការងារបៃតង និងសមរម្យ; និង
- ដាក់គោលដៅក្នុងការចាត់វិធានការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម តាមរបៀបដែលស្របជាមួយនឹងសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។

៤. ជម្រុញឲ្យមានកំណើនសេដ្ឋកិច្ច ដែលអាចធានាថា មនុស្សគ្រប់រូបមានលទ្ធភាពទទួលបាននូវស្បៀងអាហារសមរម្យ មានជីវជាតិ និងនិរន្តរភាព ព្រមទាំងទំនិញចាំបាច់ផ្សេងទៀត តាមរយៈ៖

៤.១. ការគាំទ្រវិធានការក្នុងការបង្កើនការផ្គត់ផ្គង់ស្បៀងអាហារឲ្យបានគ្រប់គ្រាន់ដោយខ្លួនឯង និងការផលិតស្បៀងអាហារ និងទំនិញចាំបាច់ផ្សេងទៀតនៅក្នុងស្រុក ប្រកបដោយនិរន្តរភាព និងមិនប៉ះពាល់ដល់បរិស្ថាន;

៤.២. ការសម្របសម្រួល ពង្រីករយៈពេល និងពង្រីកទំហំកម្មវិធីផ្តល់ជំនួយស្បៀងអាហារ និងទំនិញចាំបាច់ផ្សេងទៀតដែលមានគុណភាពដល់មនុស្សគ្រប់រូប ក្នុងតម្លៃសមរម្យ; និង

៤.៣. ការធានាថា កិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ និងតំបន់ មិនបង្កការគម្រាមកំហែងដល់លទ្ធភាពទទួលបាននូវស្បៀងអាហារដែលសមរម្យ មាននិរន្តរភាព តម្លៃសមរម្យ និងមានផាសុខភាព ព្រមទាំងទំនិញចាំបាច់ផ្សេងទៀត ក្នុងអំឡុងពេលនៃវិបត្តិ។

៥. ប្តេជ្ញាធានាថា គោលដៅ និងវិធានការនានាដូចបានរៀបរាប់ខាងលើ ត្រូវបានរៀបចំឡើង និងអនុវត្ត ដោយមានការចូលរួមយ៉ាងពេញលេញពីគ្រប់វិស័យនៃសង្គម;

៦. អំពាវនាវដល់រដ្ឋាភិបាលឲ្យពិចារណាលើការផ្តល់ថវិកាគាំទ្រវិធានការទាំងនេះ តាមរយៈការបែងចែកថវិកាឡើងវិញ ដោយកាត់ចំណាយរបស់ក្រសួងស្ថាប័ននានារបស់រដ្ឋាភិបាលដែលមិនមានតួនាទីដោយផ្ទាល់ក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺឆ្លងនេះ ដូចជា កងកម្លាំងការពារសន្តិសុខ ទុកសម្រាប់ក្រសួងស្ថាប័នដែលមានសមត្ថកិច្ច និងតាមរយៈវិភាគទានស្ម័គ្រចិត្ត និងការយកពន្ធពីក្រុមហ៊ុនសាជីវកម្ម និងបុគ្គលដែលមានទ្រព្យសម្បត្តិច្រើនជាងគេ។

៧. អញ្ជើញតួអង្គពាក់ព័ន្ធទាំងអស់ឲ្យចូលរួមជាមួយយើង ក្នុងការសម្រេចឲ្យបាននូវគោលដៅទាំងនេះ។